# *តើហេតុអ្វីបានជាមនុស្សទាំងអស់ត្រូវតែកែប្រែចិត្តជឿលើព្រះយេស៊ូវ?*

«**ពីព្រោះសេចក្ដីក្រោធរបស់ព្រះ** បានសំដែងមកពីស្ថានសួគ៌ ទាស់នឹងគ្រប់ទាំងសេចក្ដីទមិលល្មើស និងសេចក្ដីទុច្ចរិតរបស់មនុស្ស ដែលគេបង្ខាំងសេចក្ដីពិត ដោយសេចក្ដីទុច្ចរិត ២១ ព្រោះកាលគេបានស្គាល់ព្រះ នោះគេមិនបានដំកើងទ្រង់ ទុកជាព្រះទេ ក៏មិនដឹងគុណទ្រង់ដែរ គេកើតមានគំនិតឥតប្រយោជន៍វិញ ហើយចិត្តគេ ដែលឥតយោបល់ ក៏បានត្រឡប់ជាងងឹតទៅ ២២ គេអួតខ្លួនថា មានប្រាជ្ញា បានជាគេត្រឡប់ទៅជាល្ងង់ល្ងើវិញ ២៣ គឺគេបំផ្លាស់សិរីល្អនៃព្រះដែលមិនចេះខូច ឲ្យទៅជារូប មើលទៅដូចជាមនុស្ស ដែលតែងតែខូចវិញ ហើយដូចជាសត្វស្លាប សត្វជើង៤ និងសត្វលូនវារដែរ ២៤ ហេតុនោះបានជាព្រះទ្រង់ប្រគល់គេទៅឯសេចក្ដីស្មោកគ្រោក តាមចិត្តគេប្រាថ្នាចង់បាន ឲ្យបានបង្អាប់ដល់រូបកាយគេទៅវិញទៅមក ២៥ គេបានផ្លាស់សេចក្ដីពិតនៃព្រះ ឲ្យទៅជាសេចក្ដីភូតភរវិញ ក៏កោតខ្លាច ហើយគោរពប្រតិបត្តិដល់របស់ដែលកើតមក ជាជាងដល់ព្រះ ដែលបង្កើតរបស់ទាំងនោះមក ជាព្រះដែលមានព្រះពរអស់កល្បជានិច្ច អាម៉ែន» (រ៉ូម ១:១៨, ២១-២៥)

## *តើហេតុអ្វីបានជាមនុស្សទាំងអស់ត្រូវតែកែប្រែចិត្តជឿលើព្រះយេស៊ូវ? ពីព្រោះសេចក្ដីក្រោធរបស់ព្រះ បានសំដែងមកពីស្ថានសួគ៌ ទាស់នឹងមនុស្សលោក*

១០ ដូចមានសេចក្ដីចែងទុកមកថា «**គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ក៏គ្មានផង** ១១ គ្មានអ្នកណាដែលយល់ គ្មានអ្នកណាដែលស្វែងរកព្រះ ១២ គ្រប់គ្នាបានបែរចេញ ហើយត្រឡប់ជាឥតប្រយោជន៍ទាំងអស់គ្នា គ្មានអ្នកណាដែលប្រព្រឹត្តតាមសេចក្ដីសប្បុរសសោះ **តែម្នាក់ក៏គ្មានផង** ១៣ បំពង់កគេជាផ្នូរខ្មោចនៅចំហ គេប្រើអណ្ដាតគេសំរាប់នឹងបញ្ឆោត ឯនៅបបូរមាត់គេ មានសុទ្ធតែពិសពស់ហនុមាន ១៤ ហើយមាត់គេមានពេញដោយសេចក្ដីបណ្ដាសា និងសេចក្ដីជូរចត់ ១៥ ជើងគេរហ័សនឹងកំចាយឈាម ១៦ នៅអស់ទាំងផ្លូវរបស់គេ មានសុទ្ធតែសេចក្ដីវិនាស និងសេចក្ដីទុក្ខលំបាក ១៧ គេមិនបានស្គាល់ផ្លូវសុខសាន្តសោះ ១៨ ក៏គ្មានសេចក្ដីកោតខ្លាចចំពោះព្រះ នៅភ្នែកគេឡើយ» ១៩ រីឯគ្រប់ទាំងសេចក្ដីដែលក្រឹត្យវិន័យបង្គាប់ នោះយើងដឹងថា បង្គាប់ដល់តែពួកអ្នកដែលនៅក្នុងបន្ទុកក្រឹត្យវិន័យទេ ដើម្បីឲ្យគ្រប់ទាំងមាត់ត្រូវបិទ ហើយឲ្យ**លោកីយ៍ទាំងមូលជាប់មានទោសនៅចំពោះព្រះ** ២០ ហេតុនោះបានជា**គ្មានមនុស្សណាបានរាប់ជាសុចរិត នៅចំពោះទ្រង់** ដោយអាងការប្រព្រឹត្តតាមក្រឹត្យវិន័យនោះឡើយ ដ្បិតក្រឹត្យវិន័យគ្រាន់តែសំដែងឲ្យស្គាល់អំពើបាបប៉ុណ្ណោះ។ (រ៉ូម ៣:១០-២០)

*តើហេតុអ្វីបានជាមនុស្សទាំងអស់ត្រូវតែកែប្រែចិត្តជឿលើព្រះយេស៊ូវ? ពីព្រោះគ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ក៏គ្មានផង គ្មានអ្នកណាសង្គ្រោះខ្លួនបានទេ។*

«ដូច្នេះ ដែល**យើងរាល់គ្នាបានរាប់ជាសុចរិត ដោយការជឿ នោះឈ្មោះថាយើងបានមេត្រីនឹងព្រះ ដោយសារព្រះយេស៊ូវគ្រីស្ទ** ជាព្រះអម្ចាស់នៃយើងរាល់គ្នាហើយ»

«ហេតុនោះ នៅជាន់នេះ **អ្នកណាដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ នោះគ្មានទោសសោះ**»

(រ៉ូម ៥:១; ៨:១)

*តើហេតុអ្វីបានជាមនុស្សទាំងអស់ត្រូវតែកែប្រែចិត្តជឿលើព្រះយេស៊ូវ? ពីព្រោះយើងត្រូវមេត្រីនឹងព្រះ ដោយសារព្រះយេស៊ូវគ្រីស្ទ យើងចង់ឲ្យព្រះអង្គរាប់យើងជាអ្នកសុចរិត មិនមែនជាអ្នកមានទោសទៀតទេ។*

«បើមាត់អ្នកនឹងទទួលថ្លែងប្រាប់ពីព្រះអម្ចាស់យេស៊ូវ ហើយអ្នកជឿក្នុងចិត្តថា ព្រះបានប្រោសឲ្យទ្រង់រស់ពីស្លាប់ឡើងវិញ នោះអ្នកនឹង**បានសង្គ្រោះពិត** ១០ ដ្បិត**យើងបានសុចរិតដោយមានចិត្តជឿ ហើយក៏បានសង្គ្រោះ**ដោយមាត់ទទួលថ្លែងប្រាប់ ១១ ពីព្រោះគម្ពីរថា «អស់អ្នកណាជឿដល់ទ្រង់ នោះនឹងគ្មានហេតុនាំឲ្យខ្មាសឡើយ» ១២ ហើយសាសន៍យូដា និងសាសន៍ក្រេកមិនខុសអំពីគ្នាឡើយ ដ្បិតព្រះអម្ចាស់ដដែលនៃគ្រប់គ្នា ទ្រង់មានជាបរិបូរ សំរាប់អស់អ្នកណា ដែលអំពាវនាវរកទ្រង់ ១៣ ហើយគ្រប់គ្នា គឺអស់អ្នកណាដែលអំពាវនាវដល់ព្រះនាមព្រះអម្ចាស់ នោះនឹង**បានសង្គ្រោះ**» (រ៉ូម ១០:៩-១៣)

*តើហេតុអ្វីបានជាមនុស្សទាំងអស់ត្រូវតែកែប្រែចិត្តជឿលើព្រះយេស៊ូវ? ពីព្រោះយើងចង់រួចពីទោសនៃអំពើបាបរបស់ខ្លួន ហើយទទួលព្រះជាម្ចាស់ជីវិត។*

«ដោយដឹងសេចក្តីនេះថា មនុស្សចាស់របស់យើង បានត្រូវឆ្កាងជាមួយនឹងទ្រង់ហើយ ដើម្បីឲ្យតួអំពើបាបបានត្រូវសូន្យទៅ **ប្រយោជន៍កុំឲ្យយើងនៅបំរើអំពើបាបទៀតឡើយ**»

«ដូច្នេះ បងប្អូនអើយ ខ្ញុំទូន្មានអ្នករាល់គ្នា ដោយសេចក្ដីមេត្តាករុណានៃព្រះ **ឲ្យបានថ្វាយរូបកាយទុកជាយញ្ញបូជារស់** ហើយបរិសុទ្ធ ដែលគាប់ព្រះហឫទ័យដល់ព្រះ ជាការគោរពនៃអ្នករាល់គ្នា ដែលមានទំនង ២ កុំឲ្យត្រាប់តាមសម័យនេះឡើយ ចូរឲ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញ ដោយគំនិតបានកែជាថ្មីឡើង ដើម្បីនឹងអាចលមើលឲ្យបានស្គាល់បំណងព្រះហឫទ័យនៃព្រះ ដែលល្អ ស្រួលទទួល ហើយគ្រប់លក្ខណ៍ផង» (រ៉ូម ៦:៦; ១២:១-២)

*តើហេតុអ្វីបានជាមនុស្សទាំងអស់ត្រូវតែកែប្រែចិត្តជឿលើព្រះយេស៊ូវ? ពីព្រោះយើងចង់រួចពីអំណាចអំពើបាបក្នុងជីវិត ចង់ដើរតាមព្រះ*

«ឯអ្នកណាដែលជឿដល់ព្រះរាជបុត្រា នោះ**មានជីវិតដ៏នៅអស់កល្បជានិច្ចហើយ** តែអ្នកណាដែលមិនព្រមជឿដល់ព្រះរាជបុត្រាវិញ នោះនឹង**មិនឃើញជីវិតសោះឡើយ គឺសេចក្ដីក្រោធរបស់ព្រះ តែងនៅជាប់លើអ្នកនោះឯង។**» (យ៉ូហាន ៣:៣៦)

«ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលស្ដាប់ពាក្យខ្ញុំ ហើយជឿដល់ព្រះអង្គ ដែលចាត់ឲ្យខ្ញុំមក អ្នកនោះ**មានជីវិតដ៏នៅអស់កល្បជានិច្ច ហើយមិនដែលត្រូវជំនុំជំរះឡើយ គឺបានកន្លងហួសពីសេចក្ដីស្លាប់ ទៅដល់ជីវិតវិញ**» (យ៉ូហាន ៥:២៤)

«ព្រះយេស៊ូវមានព្រះបន្ទូលទៅគាត់ថា **ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ**» (យ៉ូហាន ១៤:៦)

*តើហេតុអ្វីបានជាមនុស្សទាំងអស់ត្រូវតែកែប្រែចិត្តជឿលើព្រះយេស៊ូវ? ពីព្រោះយើងចង់រួចពីសេចក្ដីក្រោធរបស់ព្រះ សេចក្ដីស្លាប់ ហើយចង់បានជីវិតដ៏នៅអស់កល្បជានិច្ចជាមួយព្រះទៅវិញ*